**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ០៤ សសរ**

# សេចក្តីសំរេច

## ស្តីពីការបន្ថែមសមាសភាពគណៈកម្មាធិការចំរុះកិច្ចការព្រំដែន កម្ពុជា-វៀតណាម

***

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៦/២៥ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន

-បានឃើញអនុក្រឹត្យលេខ១៨ អនក្រ-បក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតគណៈកម្មាធិការនីតិកម្មកិច្ចការព្រំដែន ចំណុះឱ្យអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន

-បានឃើញអនុក្រឹត្យលេខ១៩ អនក្រ-បក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតគណៈកម្មាធិការបច្ចេកទេសកិច្ចការព្រំដែន ចំណុះឱ្យអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន

-បានឃើញសេចក្តីសំរេចលេខ១៩ សសរ ចុះថ្ងៃទី៩ ខែមិនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការចំរុះកិច្ចការព្រំដែនកម្ពុជា-វៀតណាម

-តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

# សំរេច

**ប្រការ១:** ត្រូវបានបញ្ចូលសមាសភាពចំនួនពីររូបថ្មីបន្ថែមទៀត ជាសមាជិកនៃគណៈកម្មាធិការចំរុះកិច្ចការព្រំដែន កម្ពុជា-វៀតណាម គឺ :

១-លោកឧត្តមសេនីយ៍ត្រី **ម៉ោច លឹម** អនុប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន ជាសមាជិក

២-លោកវរៈសេនីយ៍ឯក **ខ្វួន សុវណ្ណា** អនុប្រធាននាយកដ្ឋានបច្ចេកទេសព្រំដែន ជាសមាជិក

**ប្រការ២:** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនិងសេចក្តីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ គណៈកម្មាធិការចំរុះកិច្ចការព្រំដែនកម្ពុជា-វៀតណាម និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមករា ឆ្នាំ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងប្រការ៣

-កាលប្បវត្តិ-ឯកសារ